អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០១៣**

# សេចក្តីថ្លែងការណ៍របស់
# ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក

បន្ទាប់ពីជំនួបកំពូលរវាងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងឯកឧត្តម **បាន គីមូន** អគ្គលេខាធិការអង្គការសហប្រជាជាតិនៅប្រទេសប្រ៊ុយណេ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ កន្លងទៅ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ថវិកាបន្ថែមចំនួន ១,៨ លានដុល្លារអាមេរិក ជាមូលនិធិសង្គ្រោះបន្ទាន់ ដល់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់ឆ្នាំ២០១៣។ សម្តេចនាយករដ្ឋមន្ត្រី និងអគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏បានអំពាវនាវផងដែរដល់សហគមន៍អន្តរជាតិ បន្តផ្តល់ជំនួយដល់ អ.វ.ត.ក ដែលកំពុងបំពេញការងារយ៉ាងសកម្មក្នុងការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។

ថវិកាបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានផ្តល់ ខណៈដែលភាគីជាតិនៃអ.វ.ត.ក កំពុងតែជួបប្រទះកង្វះសាច់ប្រាក់ សម្រាប់បើកប្រាក់ខែជូនបុគ្គលិក និងដើម្បីធានាថាភាគីជាតិអាចបំពេញការងាររបស់ខ្លួនដោយគ្មានភាពរអាក់រអួល រហូតដល់ចុងឆ្នាំ២០១៣ និងស្របពេលដែលអង្គជំនុំជម្រះសាលាដំបូងកំពុងតែដំណើរការសវនាការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលភស្តុតាងលើសំណុំរឿង ០០២/០១ ដែលឈានដល់ការចេញសាលក្រមលើសំណុំរឿងនេះ ដែលរំពឹងថានឹងត្រូវប្រកាស នៅពាក់កណ្តាលឆ្នាំ ២០១៤ ខាងមុខ។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី នៃ អ.វ.ត.ក សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសម្ចាស់ជំនួយទាំងអស់ដែលបានផ្តល់ជំនួយថវិកាដល់អ.វ.ត.កចាប់តាំងពីដំណើរការដំបូងរហូតមកដល់បច្ចុប្បន្ន។ វិភាគទានទាំងនេះគឺមានសារៈសំខាន់ណាស់ក្នុងការបំពេញអាណត្តិរបស់ខ្លួន ប្រកបដោយជោគជ័យ។ ក្នុងឱកាសនេះ ខ្ញុំក៏សូមអំពាវនាវសាជាថ្មីដល់ប្រទេសម្ចាស់ជំនួយទាំងឡាយ សូមបន្តផ្តល់វិភាគទានរបស់ខ្លួនដល់សាលាក្តីបន្តទៀតដើម្បីអនុញ្ញាតឲ្យតុលាការនេះអាចបញ្ចប់បេសកកម្មរបស់ខ្លួនក្នុងការស្វែងរកការពិតនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម។